# Healthy Incentives Program

អាហារ ស្រស់ ច្រកកំប៉ុង សម្ងួត បង្កក

## នេះគឺ HIP ដើម្បីសុខភាពល្អ!

SNAP
Supplemental
Nutrition
Assistance
Program

ការដាក់ចំណីអាហារមា
នសុខភាពល្អ

GROWING FARMERS MARKETS for 40 years
MASS FARMERS MARKETS
SINCE 1978

# គន្លឹះទិញឥវ៉ាន់ពីកម្មវិធី នៃការលើកទឹកចិត្តសុខភាព (HIP)

- ស្វែងរកអ្នកលក់រាយ HIP នៅតាមគេហទំព័រ www.mass.gov/HIP។

- ពិនិត្យមើលសមតុល្យ SNAP របស់លោកអ្នកមុនពេលលោកអ្នកទៅកាន់កសិដ្ឋាន ឬផ្សារកសិករ។ លោកអ្នកត្រូវមានសមតុល្យនៅក្នុង SNAP នៅពេលទិញពីអ្នកលក់រាយដែលចូលរួម។

- ដឹងពីចំនួនកំណត់ប្រចាំខែរបស់លោកអ្នក ផ្អែកតាមទំហំគ្រួសារ៖
  $40 (1-2 នាក់) $60 (3-5 នាក់) $80 (6+ នាក់)

- រកមើលនិមិត្តសញ្ញា HIP និងហាង! លោកអ្នកអាចទិញបន្លែ និងផ្លែឈើស្រស់ ច្រកកំប៉ុង សម្ងួត និងបង្កក។ ពួកវាមិនត្រូវបានបន្ថែមស្ករ អំបិល ខ្លាញ់ ឬប្រេងឡើយ។

- ទូទាត់ការទិញរបស់លោកអ្នកតាមរយៈកាត EBT របស់លោកអ្នក។ លោកអ្នកនឹងទទួលបាន $1 សម្រាប់ការចំណាយរាល់ដុល្លារទៅលើផ្លែឈើ និងបន្លែដែលមានសិទ្ធិទទួល រហូតដល់ចំនួនកំណត់ប្រចាំខែរបស់លោកអ្នក។ ចំនួនកំណត់ HIP របស់លោកអ្នកចាប់ផ្ដើមពីថ្ងៃទីមួយនៃខែនីមួយៗ។

- ពិនិត្យមើលបង្កាន់ដៃទទួលប្រាក់របស់លោកអ្នក។ លោកអ្នកអាចមើលឃើញចំនួន SNAP ជាដុល្លាដែលលោកអ្នកទទួលបាននៅលើបង្កាន់ដៃទទួលប្រាក់របស់លោកអ្នកក្រោយពេលលក់ HIPម្ដងៗ។ លោកអ្នកអាចចំណាយបែបនេះនៅកន្លែងដដែល ឬនៅអ្នកលក់រាយផ្សេងទៀតដែលទទួល SNAP។

- ពេលណាលោកអ្នកដល់ចំនួនកំណត់ប្រចាំខែរបស់លោកអ្នក នោះលុយ HIP នឹងមិនត្រូវបានបន្ថែមក្នុងកាតរបស់លោកអ្នកទៀតទេ។ បើលោកអ្នកចង់បាន លោកអ្នកអាចបន្តចំណាយ SNAP ដើម្បីទិញអាហារបន្ថែម។











# ដូចម្តេចដែលហៅថាផ្សារកសិករ?

ផ្សារកសិករគឺជាផ្សារមួយដែលលោកអ្នកអាចទិញផលដំណាំនៃរដូវម៉ាស្សាឈូសេត និងអាហារផ្សេងៗទៀតពីក្រុមកសិករ។

សូមចំណាយពេលដើរពេញផ្សារ និងមើលអ្វីៗគ្រប់យ៉ាងមុនពេលលោកអ្នកសម្រេចចិត្តទិញអ្វីមួយ។ ប្រៀបធៀបតម្លៃ ប្រភេទ និងគុណភាព។

បើលោកអ្នកឃើញបន្លែ ឬផ្លែឈើមិនធ្លាប់ស្គាល់ ចូរកុំខ្មាសអៀន! កសិករចូលចិត្តនិយាយពីផលដំណាំរបស់ពួកគេ ដូច្នេះចូរសួរនាំទៅ។ ពួកគេអាចនឹងឲ្យយោបល់អំពីមុខម្ហូបថ្មី។





សម្រាប់ព័ត៌មានបន្ថែម៖

## 1-800-645-8333

លេខទូរសព្ទបន្ទាន់អំពីប្រភពអាហាររបស់ Project Bread
(មាន 160 ភាសា)

## 1-800-997-2555

ពិនិត្យមើលសមតុល្យ SNAP របស់លោកអ្នក និងពិនិត្យមើលចំនួ
ជិតដល់ចំនួនកំណត់ HIP ប្រចាំខែរបស់លោកអ្នក។

លើបណ្តាញ៖www.mass.gov/HIP
អ៊ីមែល៖ dta.hip@state.ma.us